# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចព្រមព្រៀង
## រវាងតំណាងបុគ្គលិកសណ្ឋាគារ សុខាសៀមរាប
## និងនិយោជកនៃសណ្ឋាគារ សុខាសៀមរាប

អនុស្សរណៈនៃការយោគយល់នេះត្រូវបានធ្វើឡើងនៅថ្ងៃទី ២៣ ខែមេសា ឆ្នាំ២០២០ រវាងប្រធានផ្នែកនៃសណ្ឋាគារ សុខាសៀមរាប (ពីនេះតទៅហៅថា "**តំណាងបុគ្គលិក**") និងតំណាងសណ្ឋាគារ សុខាសៀមរាប (ពីនេះតទៅហៅថា "**និយោជក**")។

ដោយសារតែការផ្ទុះឡើងនូវជំងឺកូវីត ១៩ ដែលកំពុងតែឆ្លងរាលដាលយ៉ាងខ្លាំង នៅទូទាំងពិភពលោកនាពេលនេះ បានធ្វើឲ្យអាជីវកម្មសណ្ឋាគារ សុខាសៀមរាបជួបប្រទះនូវការលំបាកផ្នែកហិរញ្ញវត្ថុយ៉ាងធ្ងន់ធ្ងរបំផុត។ ហេតុនេះ ដើម្បីសម្រាលនូវបញ្ហាប្រឈមដ៏ធ្ងន់ធ្ងរនៅចំពោះមុខនេះ និយោជក និងតំណាងបុគ្គលិកបានចរចារ និងព្រមព្រាងគ្នាដាក់ឲ្យបុគ្គលិកមួយភាគធំឈប់សម្រាកពីការងារដោយឥតប្រាក់ឈ្នួល រយៈពេលពីរ (២) ខែ គិតចាប់ពីថ្ងៃទី ០១ ខែមេសា ដល់ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ ២០២០។

ភាគីទាំងពីរបានព្រមព្រៀងគ្នា លើលក្ខខណ្ឌដូចខាងក្រោម៖

- និយោជិតដែលត្រូវបានដាក់ឲ្យឈប់សម្រាកពីការងាររយៈពេលពីរ (២) ខែ នឹងមិនទទួលបានប្រាក់ឈ្នួល និងប្រាក់ធានានុគ្រោះទេ នៅក្នុងអំឡុងពេលនៃការឈប់សម្រាកនេះ។
- អតីតភាពការងាររបស់និយោជិតដែលដាក់ឲ្យឈប់សម្រាកដោយឥតប្រាក់ឈ្នួល នឹងមិនត្រូវបានប៉ះពាល់ឡើយ។
- ដើម្បីសម្រួលដល់ជីវភាពនិយោជិត នៅក្នុងអំឡុងពេលនៃការឈប់សម្រាកពីការងារដោយឥតប្រាក់ឈ្នួលរយៈពេលពីរ (២) ខែនេះ និយោជកបានសម្រេចដកប្រាក់មូលនិធិជំនួយបន្ទាន់ស្មើរតែ ១០០% មកបែងចែកជូននិយោជិតសណ្ឋាគារទាំងអស់ ដែលមានចំនួនសរុប ៥៤០ នាក់ ដែលជាមធ្យមនិយោជិតម្នាក់ៗទទួលបានប្រាក់មូលនិធិជំនួយបន្ទាន់នេះចំនួន ២១៥.៤២ដុល្លារអាមេរិក។

ចំពោះនិយោជិតដែលត្រូវរក្សាទុកក្នុងចំនួនអប្បបរមា ទៅតាមតម្រូវការជាក់ស្តែងនៃផ្នែកនីមួយៗសម្រាប់ធ្វើការពេញម៉ោង (៤សប្តាហ៍) ក្នុងមួយខែ៖

- និយោជិតធម្មតានឹងទទួលបានប្រាក់ឈ្នួល ១០០%។
- និយោជិតថ្នាក់ប្រធាន/អនុប្រធានផ្នែក នឹងទទួលបានប្រាក់ឈ្នួល ៥០% នៃប្រាក់ខែគោលព្រមទាំងប្រាក់ ឧបត្ថម្ភអាហារចំនួន ៥.០០ដុល្លារអាមេរិក សម្រាប់ ១ថ្ងៃធ្វើការ។
- និយោជិតថ្នាក់ប្រធាន/អនុប្រធានផ្នែក ដែលតម្រូវឲ្យធ្វើការបួន (៤) ថ្ងៃក្នុងមួយខែ នឹងទទួល

បានប្រាក់ឈ្នួល ៥០% នៃប្រាក់ខែគោល ដោយគណនាទៅតាមចំនួនថ្ងៃធ្វើការជាក់ស្តែងរបស់និយោជិតនីមួយៗ ព្រមទាំងប្រាក់ឧបត្ថម្ភអាហារចំនួន ៥.០០ដុល្លារអាមេរិក សម្រាប់ ១ ថ្ងៃធ្វើការ។

- និយោជិតថ្នាក់គ្រប់គ្រងទូទៅ និងគ្រប់គ្រងប្រតិបត្តិការត្រូវធ្វើការពេញម៉ោង ដោយមិនទទួលបានប្រាក់បៀវត្ស។

សូមបញ្ជាក់ថា ចំណុចដូចដែលបានរៀបរាប់ខាងលើនេះ គឺសម្រាប់ការអនុវត្តរយៈពេលពីរ (២) ខែ គិតចាប់ពីថ្ងៃទី០១ ខែមេសា ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២០។ ក្រុមហ៊ុននឹងធ្វើការជូនដំណឹងជាថ្មី ប្រសិនបើស្ថានការណ៍មានការប្រែប្រួល ហើយគូភាគីនឹងពិនិត្យមើលអនុស្សរណៈនៃការយោគយល់នេះ ពីខាងក្រោមនេះ៖

**ហត្ថលេខាភាគីតំណាងនិយោជក**

សណ្ឋាគារសុខាសៀមរាប SOKHA SIEM REAP HOTEL BRANCH OF SOKHA HOTEL CO., LTD

________________

**ហត្ថលេខាភាគីតំណាងនិយោជិត**

នន់ ស៊ីដា ________________

សំ រចនា ________________

ជួន វីរៈ ________________

ឈា ឆង ________________

សំ សុភ័ណ្ឌ ________________

គុណ ថាណែត ________________

ហេង សារី ________________

នល់ ស៊ាង ________________

ង៉ែត សុខា ________________

លី សត្យា ________________